# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ៨២,៦១៥ ដុល្លារអាមេរិក សម្រាប់គម្រោងជួសជុលអគារជម្ងឺឆ្លងក្នុង មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ (វិស័យសុខាភិបាល)



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ៨២,៦១៥ ដុល្លាអាមេរិក ដល់មន្ទីរសុខាភិបាលខេត្តកំពង់ធំ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកវេជ្ជបណ្ឌិត ស្រី ស៊ីន ប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ធំ នៅស្ថានទូតជប៉ុន ដើម្បីអនុវត្ត "គម្រោងជួសជុលអគារជម្ងឺឆ្លងក្នុងមន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ"។

ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពនៅខេត្តកំពង់ធំ មន្ទីរសុខាភិបាលខេត្តកំពង់ធំនឹងជួសជុលអាគារទ្រុឌទ្រោមឡើងវិញ និងសម្រួលនូវស្ថានភាពសុខភាពនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ។ យើងរំពឹងថានៅពេលគម្រោងនេះត្រូវបានបញ្ចប់ ប្រជាជនប្រមាណ ៦៦០,០០០ នាក់នៅក្នុងតំបន់គោលដៅ នឹងទទួលផលប្រយោជន៍តាមរយៈគម្រោងនេះ។

កម្មវិធីជំនួយឥតសំណងរបស់ជប៉ុន (ជំនួយគូសាណូណេ) បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្ថាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកា ៥២លានដុល្លាអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៥១៩ គម្រោងនៅទូទាំងប្រទេស។





*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*